# ការបង្កើតភាពជាដៃគូអន្តរាគមន៍បឋមវ័យជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក

# តម្រុយចេញពី និង សម្រាប់មាតាបិតា



Washington State Department of
Early Learning

Early Support
for Infants
and Toddlers



Washington State Department of
Early Learning

Early Support for Infants and Toddlers

PO Box 40970
Olympia, Washington 98504-0970
ទូរស័ព្ទ ៖ 360-725-3500
ទូរសារ ៖ 360-413-3482
គេហទំព័រ ៖ www.del.wa.gov/esit

ក្នុងឋានន្តជាឪពុកម្តាយ, លោកអ្នកស្គាល់កូនរបស់លោកអ្នកច្បាស់លាស់ជាងមនុស្សណាៗទាំងអស់។ លោកអ្នកដឹងអំពីរបៀបធ្វើឲ្យវាសើច និងរបៀបធ្វើឲ្យវាឈប់សើច។ លោកអ្នកដឹងអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់វា ព្រមទាំងដឹងអំពីអ្វីដែលវាត្រូវការជាចម្បងផង។

ដូច្នេះ នៅពេលកូនរបស់លោកអ្នកទទួលសេវាអន្តរាគមន៍បឋមវ័យ, នោះលោកអ្នកគឺជាមនុស្សគន្លឹះក្នុងការជួយប្រាប់ប្រងវេជ្ជបណ្ឌិត* របស់កូនលោកអ្នក ឲ្យដឹង និងយល់អំពីចំណុចខ្លាំង និងសេចក្តីត្រូវការរបស់កូនលោកអ្នក, និងអំពីប្រភេទសេវាកម្មដែលអាចជួយកូនរបស់លោកអ្នក។

លោកអ្នកអាចប្រាប់វេជ្ជបណ្ឌិតរបស់កូនលោកអ្នកជាបន្ថែមដើម្បីឲ្យគេបានជ្រាបអំពីដំណើរការ ដែលលោកអ្នកផ្តល់កម្មវិធីអន្តរាគមន៍បឋមវ័យដល់កូនរបស់លោកអ្នក, ហើយលោកអ្នកក៏ប្រហែលជាចង់ឲ្យវេជ្ជបណ្ឌិតរូបនេះបានចូលរួមក្នុងដំណើរការនេះផងដែរ។ "ភាពជាដៃគូអន្តរាគមន៍បឋមវ័យ" ("Early Intervention Partnership") រវាងបណ្តាវេជ្ជបណ្ឌិត និងឪពុកម្តាយមិនកើតឡើងដោយឯកឯងនោះទេ។ ជាក់ស្តែង, វាអាចកើតឡើងដោយជោគជ័យទៅបានលុះត្រាណាតែឪពុកម្តាយ– លោកអ្នក – បានធ្វើឲ្យវាកើតឡើង!

មានជំហានជាច្រើនដែលលោកអ្នកអាចអនុវត្ត ដើម្បីបង្កើតប្រភេទនៃភាពជាដៃគូ និងទំនាក់ទំនង ដែលអ្នកចង់បានជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក។ កូនសៀវភៅនេះនឹងផ្តល់ជូនលោកអ្នកនូវអនុសាសន៍ និងគំនិតល្អៗសម្រាប់ការចាប់ផ្តើមជាមួយវេជ្ជបណ្ឌិតថ្មីណាម្នាក់ ហើយក៏សម្រាប់ការបង្កើនភាពជាដៃគូណាមួយ ដែលលោកអ្នកមានរួចទៅហើយនោះ ឲ្យរឹតតែបានល្អប្រសើរឡើងផងដែរ។

** ដើម្បីឲ្យងាយស្រួល, យើងប្រើពាក្យ "វេជ្ជបណ្ឌិត" ប៉ុន្តែអត្ថន័យទូទៅនៃពាក្យនេះមិនសំដៅតែលើវេជ្ជបណ្ឌិតមួយមុខប៉ុណ្ណោះទេ តែក៏សំដៅលើគ្រប់អ្នកផ្តល់សេវាថែទាំសុខភាពបឋមដទៃៗទៀតផងដែរ ដូចជាគិលានុបដ្ឋាកប្រាក់ធីសស៊ីននើរ, ជំនួយការរបស់គ្រូពេទ្យ, និងអ្នកថែទាំសុខភាពដទៃៗទៀត។*

# ការជ្រើសរើសវេជ្ជបណ្ឌិត

នេះជាគុណភាពទូទៅមួយចំនួនដែលគួរស្វែងរក ៖

### ជំនាញនិងចំណេះដឹងខាងការព្យាបាលអ្នកជម្ងឺ

តើវេជ្ជបណ្ឌិតរូបនេះមានចំណេះដឹង និងចំណាប់អារម្មណ៍ពិសេស ដែលសំខាន់ចំពោះសេចក្ដីត្រូវការនានារបស់កូនលោកអ្នកឬទេ?

វេជ្ជបណ្ឌិត ដែលមានចំណាប់អារម្មណ៍ជាពិសេសលើការអភិវឌ្ឍន៍, លើសេចក្ដីត្រូវការពិសេស, ឬលើការធ្វើរោគវិនិច្ឆ័យជាក់លាក់ គឺអាចជាវេជ្ជបណ្ឌិតសមរម្យមួយរូប ដែលលោកអ្នកកំពុងស្វែងរកនោះហើយ។

### បទពិសោធន៍

តើវេជ្ជបណ្ឌិតរូបនេះបានយកចិត្តទុកដាក់ចំពោះក្មេងដទៃៗទៀត ដែលមានជម្ងឺប្រហាក់ប្រហែលគ្នានឹងកូនរបស់លោកអ្នក ឬបណ្ដាក្មេងដែលមានការយឺតយ៉ាវផ្នែកអភិវឌ្ឍន៍កាយសម្បទា ឬដែលមានពិការភាពជាទូទៅឬទេ?

បទពិសោធន៍ប្រភេទនេះនឹងជួយវេជ្ជបណ្ឌិតរបស់លោកអ្នកឲ្យស្គាល់ធនធានជំនួយ និងសេវាកម្មនានា ដែលកំពុងមានបម្រើការជុំវិញខ្លួន ដែលកូន និងគ្រួសាររបស់លោកអ្នកអាចទាញយកអត្ថប្រយោជន៍បាន។

### ការគោរពគ្នាទៅវិញទៅមកនិងអារម្មណ៍ស្និទ្ធស្នាល

តើវេជ្ជបណ្ឌិតរូបនេះមានចរិតស្លូតបូតឬទេ? តើវេជ្ជបណ្ឌិតរូបនេះធ្វើឲ្យលោកអ្នកមានការកក់ក្ដៅឬទេ? តើលោកអ្នកពេញចិត្តនឹងការប្រស្រ័យទាក់ទងរបស់គាត់ជាមួយកូនរបស់លោកអ្នកឬទេ?

តើលោកអ្នកទុកចិត្តឲ្យវេជ្ជបណ្ឌិតរូបនេះថែទាំសុខភាពរបស់កូនលោកអ្នកឬទេ?

វេជ្ជបណ្ឌិតម្នាក់ប៉ុនប្រសប់ខាងនេះ តែខ្វះខាងនោះ។ ដូច្នេះ ការជ្រើសរើសវេជ្ជបណ្ឌិតអាចមានន័យដូចជាការជ្រើសរើសតុល្យភាពរវាងជំនាញខាងបច្ចេកទេស, ជំនាញខាងទំនាក់ទំនង, និងបទពិសោធន៍។

លោកអ្នកត្រូវសម្រេចអំពីអ្វីដែលលោកអ្នកចង់បាន និងអ្វីដែលកូនលោកអ្នកត្រូវការនៅពេលនេះ។ លោកអ្នកអាចនឹងរកឃើញថា អ្វីដែលលោកអ្នកត្រូវការនៅពេលនេះ វានឹងប្រែប្រួលនៅពេលក្រោយ។

# ការបង្កើតទំនាក់ទំនង

### ធ្វើជាដៃគូ

ចូរសម្រេចមើល ថាតើលោកអ្នកចង់បានភាពជាដៃគូប្រភេទណាជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក។ តើលោកអ្នកចង់ឲ្យវេជ្ជបណ្ឌិតរូបនេះចូលរួមក្នុងការសម្របសម្រួលការថែទាំសុខភាព និងការផ្ដល់សេវាបម្រើកូនរបស់លោកអ្នកដោយរបៀបណា? តើលោកអ្នកចង់មានតួនាទីអ្វីខ្លះក្នុងការធ្វើសេចក្ដីសម្រេចអំពីការព្យាបាល និងការថែទាំសុខភាពរបស់កូនលោកអ្នក?

ទោះលោកអ្នកមានភាពជាដៃគូប្រភេទណាក៏ដោយ, តែលោកអ្នកត្រូវតែមានអារម្មណ៍កក់ក្ដៅក្នុងសាកសួរសំណួរផ្សេងៗ, ចែករំលែកទស្សនៈយល់ឃើញរបស់លោកអ្នក, និងមានអារម្មណ៍ថា លោកអ្នក ហើយនិងវេជ្ជបណ្ឌិតរូបនេះជាមនុស្សល្អកល្អិនក្នុងក្រុមតែមួយ។

ឯលោកអ្នកក៏ត្រូវតែបើកចិត្តគំនិតស្វាគមន៍សំណួរ និងទស្សនៈយល់ឃើញរបស់វេជ្ជបណ្ឌិត ហើយព្រមទទួលរូបគាត់ ឬការរួមចំណែករបស់គាត់ ទុកជាមនុស្សល្អកល្អិនក្នុងក្រុមរបស់កូនលោកអ្នកដូចគ្នាអញ្ចឹងដែរ។

### ធ្វើជាគំរូ

ចូរធ្វើគំរូ ដើម្បីបង្ហាញអំពីរបៀបដែលលោកអ្នកចង់ឲ្យគេរាប់អានលោកអ្នក និងកូនរបស់លោកអ្នក។

បើលោកអ្នកចង់ឲ្យគេស្ដាប់លោកអ្នក, នោះលោកអ្នកត្រូវតែធ្វើខ្លួនជាមនុស្សល្អ ដែលចេះស្ដាប់គេដែរ។ បើលោកអ្នកចង់ឲ្យវេជ្ជបណ្ឌិតរបស់លោកអ្នករាក់ទាក់នឹងកូននឹងកូនរបស់លោកអ្នក, នោះលោកអ្នកត្រូវតែបង្ហាញអំពីភាពរាក់ទាក់របស់លោកអ្នកជាមួយកូនរបស់លោកអ្នក។

### ធ្វើជាអ្នកយល់ការរាក់ជ្រៅ

វេជ្ជបណ្ឌិតត្រូវតែដាក់ពេលណាត់ជួបជាមួយមនុស្សម្នាជាទូទៅសឹងគ្រប់ពេល, រៀងរាល់ 15 នាទីម្ដង ឬអាចញឹកញាប់ជាងនេះផង។ បើលោកអ្នកសម្គាល់ឃើញថា វេជ្ជបណ្ឌិតរូបនេះដូចជាប្រញាប់ទៅជួបនរណាផ្សេងទៀត, នោះលោកអ្នកប្រហែលជាសម្គាល់ឃើញត្រូវហើយ!

បើអ្នកត្រូវការពេលបន្ថែម, ចូរប្រាប់វេជ្ជបណ្ឌិត នោះគាត់នឹងជួយសម្រួលពេលវេលាជូនអ្នក។ សូមអានមើលផ្នែក *ការទាញយកអត្ថប្រយោជន៍ពីការណាត់ជួប* ដើម្បីស្វែងយល់គំនិតជាក់លាក់ស្ដីអំពីការប្រើពេលវេលា។

### អនុញ្ញាតឲ្យវេជ្ជបណ្ឌិតបានស្គាល់កូនរបស់លោកអ្នករឹតតែច្បាស់

ចូរនិយាយអំពីសេចក្ដីល្អ និងក្ដីបារម្ភរបស់លោកអ្នកប្រាប់វេជ្ជបណ្ឌិតឲ្យបានច្រើន។ ចូរបង្ហាញរូបថត និងប្រាប់រឿងរ៉ាវនានា ដើម្បីឲ្យវេជ្ជបណ្ឌិតអាចរាប់អាន ព្រមទាំងស្គាល់កូនរបស់លោកអ្នករឹងតែច្បាស់។

### សម្ដែងអំណរគុណ

គប្បីថ្លែងអំណរគុណដល់វេជ្ជបណ្ឌិតរបស់លោកអ្នក ដោយផ្ទាល់មាត់ក៏បាន ឬដោយការសរសេរសំបុត្រលាយលក្ខណ៍អក្សរក៏បាន។ ចូរប្រាប់គាត់ឲ្យបានដឹងអំពីអ្វីដែលគាត់បានធ្វើ ហើយបានក្លាយជាជំនួយដល់គ្រួសាររបស់លោកអ្នក និងអ្វីដែលគាត់បានធ្វើ ហើយបានក្លាយជាសេចក្ដីល្អ ដើម្បីបម្រើផលប្រយោជន៍នៃគ្រួសាររបស់លោកអ្នក។

### កុំរំពឹងការល្អឥតខ្ចោះ

គ្រប់ទំនាក់ទំនងទាំងអស់តែងតែមានក្តីល្អក់កករគ្រោតគ្រាតឯទំនាក់ទំនងមួយនេះក៏ដូច្នោះដែរ។ ត្រូវចេះសម្របសម្រួលទៅតាមកាល្លទេស្ល ប្រសិនបើចាំបាច់។ ត្រូវទទួលស្គាល់ថា វេជ្ជបណ្ឌិតក៏ជាមនុស្សដែរ ដូច្នេះ ចូរទុកឱកាសឲ្យគាត់បានកែច្នៃសេចក្តីឆ្គាំឆ្គង ឲ្យបានល្អប្រសើរឡើងវិញ។

បើលោកអ្នកស្រឡាញ់ពេញចិត្តវេជ្ជបណ្ឌិតរបស់កូនលោកអ្នក, នោះលោកអ្នកគប្បីចេះអត់ឱនដល់ការឆ្គាំឆ្គង ដែលតែងតែកើតឡើងម្តងម្កាល។

សូមអានមើលផ្នែក *ការសម្រេចចិត្តផ្លាស់ប្តូរវេជ្ជបណ្ឌិត* ដើម្បីស្វែងយល់ពត៌មានពិស្តារស្តីអំពីពេលវេលា ដែលលោកអ្នកអាចសម្រេចចិត្តធ្វើការផ្លាស់ប្តូរ។

## ការរក្សាខ្ជាប់នូវការទាក់ទងគ្នាល្អ

### ការសន្ទនាពីរច្រក

សូមចាត់ទុកការនិយាយទាក់ទងគ្នាជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នកថាជាការសន្ទនាដោយមិត្តភាពនិងគោរពគ្នាទៅវិញទៅមក។ ការធ្វើដូច្នោះមានន័យថា ជាការសន្ទនាពីរច្រក ដែលភាគីម្ខាងៗគប្បីឡើកយកសំណួរ, ក្តីបារម្ភ, ជោគជ័យ, និងក្តីសង្ឃឹម ទៅពិគ្រោះគ្នាក្នុងការសន្ទនានោះ។

### យល់ឲ្យច្បាស់អំពីរបៀបនិយាយទាក់ទងគ្នា

ចូរសួរវេជ្ជបណ្ឌិតអំពីរបៀបនិយាយទាក់ទងគ្នាល្អអំពីការថែទាំសុខភាពរបស់កូនលោកអ្នក។

តើមានពេលវេលាណាមួយល្អសមរម្យ ដើម្បីអ្នកទាំងពីរអាចទូរស័ព្ទនិយាយគ្នានៅក្នុងអំឡុងពេលថ្ងៃឬទេ?

តើវេជ្ជបណ្ឌិតយក់ថា ជាដំបូង លោកអ្នកគួរនិយាយជាមួយគិលានុបដ្ឋាយិកាប្រចាំការិយាល័យ ប្រសិនបើលោកអ្នកមានសំណួរ នៅចន្លោះពេលណាត់ជួបឬយ៉ាងណា?

តើនឹងមានកាល្លទេស្លពិសេសណា ដែលវេជ្ជបណ្ឌិតចង់ឲ្យលោកអ្នកទូរស័ព្ទទៅជួបគាត់នៅផ្ទះឬយ៉ាងណា?

តើវេជ្ជបណ្ឌិតរបស់លោកអ្នកស្វាគមន៍ការទាក់ទងតាមអ៊ីមែលទេ? តាមទូរសារ? តាមមធ្យោបាយផ្សេងៗទៀត?

### កុំខ្លាចបើត្រូវការឱវាទនៅចន្លោះពេលណាត់ជួប

បើលោកអ្នកមានក្តីបារម្ភណាមួយនៅចន្លោះពេលណាត់ជួប ហើយមានអារម្មណ៍ថា លោកអ្នកត្រូវការ ឬចង់បានការឆ្លើយបំភ្លឺពីវេជ្ជបណ្ឌិតរបស់កូនលោកអ្នក, នោះចូរស្នើសុំគិលានុបដ្ឋាយិកា ឲ្យប្រាប់វេជ្ជបណ្ឌិត ឲ្យទូរស័ព្ទទៅលោកអ្នកកុំខាន។

ចូរពន្យល់ថា លោកអ្នកមានការព្រួយបារម្ភខុសប្លែកធម្មតា – ចំពោះមូលហេតុដែលលោកអ្នកមិនទាន់អាចពន្យល់ប្រាប់បាននៅឡើយ – ហើយថា លោកអ្នកចង់និយាយជាមួយវេជ្ជបណ្ឌិតដោយផ្ទាល់។

### ការរិះគិតមើលមុខមើលក្រោយ

តើលោកអ្នកមានបានពិភាក្សាអំពីសំណួរ ឬបញ្ហាសំខាន់ៗជាមួយវេជ្ជបណ្ឌិតឬទេ? បើគ្មានទេ, តើលោកអ្នកយល់ថារឿងនោះជារឿងធម្មតាឬយ៉ាងណា ឬមួយក៏លោកអ្នកបានត្រៀមផែនការអ្វីមួយ ដើម្បីស្វែងរកពត៌មានដែលលោកអ្នកត្រូវការទាំងនោះរួចជាស្រេចទៅហើយ?

តើលោកអ្នកមានមានអារម្មណ៍យល់ថា លោកអ្នកជាដៃគូម្នាក់ក្នុងក្រុមថែទាំសុខភាពរបស់កូនលោកអ្នកឬទេ? តើលោកអ្នកមានគិតឃើញថា ទៅថ្ងៃមុខលោកអ្នកគួរធ្វើអ្វីមួយប្លែក ដើម្បីឲ្យបានល្អប្រសើរជាងនេះឬទេ?

## ការសម្រេចចិត្តផ្លាស់ប្តូរវេជ្ជបណ្ឌិត

ឪពុកម្តាយភាគច្រើនពេញចិត្តនឹងវេជ្ជបណ្ឌិតរបស់កូនពួកគេ។ តែក៏មានពេលខ្លះ អ្វីៗអាចមានដំណើរប្រព្រឹតទៅមិនប្រក្រតីដែរ។ ដូច្នេះ ខាងក្រោមនេះគឺជាសំណួរខ្លះៗដែលលោកអ្នកគួរចោទសួរខ្លួនឯង ៖

- របៀបដែលការិយាល័យវេជ្ជបណ្ឌិតធ្វើការសព្វថ្ងៃនេះ តើពេញចិត្តលោកអ្នកឬទេ?
- នៅពេលលោកអ្នកត្រូវការគាត់ តើវេជ្ជបណ្ឌិតរូបនេះមានពេលវេលាសម្រាប់លោកអ្នកឬទេ?
- ជាញយៗ តើលោកអ្នកមានដែលងឿងឆ្ងល់ទេថា ហេតុអ្វីបានជាការទូន្មានជួយកាលបែរជាត្រូវគេចេញវេជ្ជបញ្ជា ឲ្យព្យាបាលនេះព្យាបាលនោះទៅវិញ?
- តើលោកអ្នកមានដែលមានអារម្មណ៍យល់ថា សេចក្តីបារម្ភរបស់លោកអ្នកមិនត្រូវបានគេយកចិត្តទុកដាក់ឬទេ? តើការនេះបានធ្វើឲ្យលោកអ្នកសង្ស័យ ហើយមិនទុកចិត្តលើការវិនិច្ឆ័យរបស់ខ្លួនឬរបស់វេជ្ជបណ្ឌិតរបស់លោកអ្នកឬទេ?

ចូរទុកចិត្តលើសុភវិនិច្ឆ័យរបស់ខ្លួន។ បើទំនាក់ទំនងមួយនេះមិនធ្វើឲ្យលោកអ្នកមានអារម្មណ៍កក់ក្តៅទេ ហើយលោកអ្នកបានខិតខំដែរ តែមិនអាចកែច្នៃឲ្យវាបានល្អប្រសើរឡើងទៅបាន, នោះល្មមដល់ពេលផ្លាស់ប្តូរវេជ្ជបណ្ឌិតហើយ។

សូមព្យាយាមផ្លាស់ប្តូរដោយសុភាពរាបសា។

> *"ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូពេទ្យ ដែលបានធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់កូនខ្ញុំ។ ខ្ញុំរីករាយណាស់ ដែលលោកគ្រូបានចំណាយពេលជាមួយយើងខ្ញុំ។ តែពេលនៅនេះខ្ញុំយល់ថា កាល្លទេស្លមិនអំណោយផលសម្រាប់គ្រួសារយើងខ្ញុំទេ – ដូច្នេះ ខ្ញុំសូមលោកគ្រូមេត្តាយោគយល់ ដ្បិតខ្ញុំចង់រកគ្រូពេទ្យម្នាក់ទៀតសម្រាប់កូនខ្ញុំ។"*

## ការចូលរួមជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នកក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ

វេជ្ជបណ្ឌិតមានចំណូលចិត្ត ហើយចង់ចូលរួមក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ (Early Intervention Program) របស់ក្មេង។ ក៏ប៉ុន្តែភាពមមាញឹកអាចនឹងកាត់ផ្តាច់ពួកគាត់ពីការចូលរួមសកម្មក្នុងកម្មវិធីនេះ។

បើលោកអ្នកចង់បញ្ចូលវេជ្ជបណ្ឌិតរបស់លោកអ្នកក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ, សូមអញ្ជើញគាត់ឲ្យជួយផ្តល់គំនិតយោបល់ផ្សេងៗដល់លោកអ្នក។ នៅពេលណាលោកអ្នកធ្វើដូច្នេះ, នោះមានន័យថា លោកអ្នកបានបង្កើតភាពជាដៃគូអន្តរាគមន៍មួយហើយ!

ខាងក្រោមនេះគឺជាសេចក្តីណែនាំខ្លះៗ ៖

### ផ្តល់ពត៌មាន

ចូរឲ្យប្រាកដថា វេជ្ជបណ្ឌិតរបស់លោកអ្នកមានឈ្មោះនៅក្នុងបញ្ជីកម្មវិធីទាំងអស់របស់កូនលោកអ្នក។

នៅពេលទៅជួបវេជ្ជបណ្ឌិត, ចូរនាំយកអស់ទាំងរបាយការណ៍ពិសេសៗ ដែលលោកអ្នកចង់ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ជាប់ទៅតាមខ្លួន។

ចូរធ្វើជាអ្នកផ្សារភ្ជាប់វេជ្ជបណ្ឌិតទៅនឹងកម្មវិធីអន្តរាគមន៍បឋមវ័យ – ចូរចែករំលែកសំណួរ និងកង្វល់នានាទៅវិញទៅមកជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក។

### អញ្ជើញ

ចូរសាកសួរថាតើវេជ្ជបណ្ឌិតរបស់លោកអ្នកអាចអញ្ជើញចូលរួមកិច្ចប្រជុំផែនការសេវាគ្រួសារតម្រូវតាមស្ថានភាពបុគ្គល (Individualized Family Service Plan, IFSP) ឬកិច្ចប្រជុំផ្សេងៗទៀតបានទេ។ សួរគាត់អំពីពេលវេលា និងទីកន្លែងសមរម្យ ដែលគាត់អាចចូលរួមបាន។

វេជ្ជបណ្ឌិតរបស់លោកអ្នកប្រហែលអាចចូលរួមនៅពេលណា ដែលគាត់ទំនេរពីការណាត់ជួបអ្នកជម្ងឺ, ដូចជានៅពេលព្រឹកមុនម៉ោងធ្វើការ ឬនៅពេលល្ងាចក្រោយម៉ោងធ្វើការជាដើម។ ការបើកកិច្ចប្រជុំក្រុមការងារនៅក្នុងការិយាល័យវេជ្ជបណ្ឌិតអាចធ្វើឲ្យគាត់ងាយស្រួលចូលរួម។

## ការទាញយកអត្ថប្រយោជន៍ពីការណាត់ជួប

### ការដាក់ពេលណាត់ជួប

ចូរដាក់ពេលណាត់ជួបវេជ្ជបណ្ឌិតសម្រាប់ការណាត់ជួបលើកដំបូងនៅពេលថ្ងៃ ឬនៅក្រោយពេលបាយថ្ងៃត្រង់ បើសិនជាលោកអ្នកចង់កាត់បន្ថយការរង់ចាំយូរ។

បើលោកអ្នកមានសំណួរឬកង្វល់ផ្សេងៗ ដែលអាចនឹងស៊ីពេលយូរជាងធម្មតា, នោះចូរសុំបុគ្គលិកការិយាល័យឲ្យដាក់ពេលណាត់ជួបឲ្យបានយូរ។ វេជ្ជបណ្ឌិតរបស់លោកអ្នក និងបុគ្គលិកនឹងមានចិត្តត្រេកអរចំពោះការជូនដំណឹងជាមុននេះ ហើយលោកអ្នកក៏នឹងមានអារម្មណ៍ធូរស្រាលច្រើនចំពោះការគ្មានពេលវេលាគ្រប់គ្រាន់ដែរ។

### ការត្រៀមជាមុន

ចូរគិតមើលអំពីអ្វីដែលលោកអ្នកចង់បានពីការណាត់ជួបនេះឲ្យបានស្រេចបាច់ជាមុន ៖

- ចូរធ្វើបញ្ជីមួយ ដើម្បីកត់សំណួរ, កង្វល់, និងពត៌មានដែលលោកអ្នកចង់ចែករំលែកជាមួយវេជ្ជបណ្ឌិត។
- វាជាការធម្មតាក្នុងការលើកយកបញ្ហានានា ដែលហាក់មិនសូវពាក់ព័ន្ធសុខភាព ប៉ុន្តែដែលមានសារសំខាន់សម្រាប់លោកអ្នក និងកូនរបស់លោកអ្នក។
- ចូរសម្រេចមើលអំពីអ្វីដែលគួរដាក់ក្នុងបញ្ជីរបស់លោកអ្នក ដែលមានសារសំខាន់បំផុតសម្រាប់លោកអ្នក។

ចូរសួរវេជ្ជបណ្ឌិតថាតើគាត់ចង់បានសំណៅចម្លងនៃសំណួរ និងកង្វល់របស់លោកអ្នក ឲ្យបានមុនពេលណាត់ជួបឬទេ។ ការផ្ញើបញ្ជីនេះជូនទៅវេជ្ជបណ្ឌិតតាមអ៊ីមែល, តាមទូរសារ, ឬតាមការយកទៅជូនផ្ទាល់ដៃ ឲ្យបានមុនពេលណាត់ជួបអាចផ្តល់ពេលគ្រប់គ្រាន់ជូនវេជ្ជបណ្ឌិត ដើម្បីរិះរកចម្លើយពេញលេញ ដើម្បីឆ្លើយតបសំណួររបស់លោកអ្នក។



## ការចូលរួម

ចូរចែករំលែកបញ្ជីសំណួរ និងកង្វល់របស់លោកអ្នកជាមួយវេជ្ជបណ្ឌិត នៅពេលចាប់ផ្តើមការណាត់ជួប។ វេជ្ជបណ្ឌិតទំនងជានឹងមានបញ្ជីមួយរបស់ផងគាត់រួចទៅហើយ សំរាប់អ្វីដែលគាត់ត្រូវធ្វើនៅក្នុងពេលណាត់ជួបនេះ។ លោកអ្នកគួរពិគ្រោះជាមួយវេជ្ជបណ្ឌិតអំពីអ្វីដែលគួរនិយាយគ្នានៅក្នុងពេលណាត់ជួបនេះ និងអ្វីដែលគួរនិយាយគ្នានៅពេលក្រោយៗទៀត។

នៅក្នុងអំឡុងពេលណាត់ជួប, រឿងរ៉ាវជាច្រើនអាចកើតឡើងជួនគ្នាយ៉ាងឆាប់រហ័ស ដែលជាហេតុនាំឲ្យពិកបាកចងចាំគ្រប់ពាក្យសម្តី ដែលបាននិយាយគ្នាក្នុងគ្រានោះ។ ខាងក្រោមនេះគឺជាគំនិតខ្លះៗ ដើម្បីជួយការចងចាំ ៖

- កត់ទុក។ ចូរប្រើសៀវភៅដដែលៗ ដើម្បីកត់សំណួរ និងចម្លើយរបស់លោកអ្នកនៅក្នុងពេលណាត់ជួបម្តងៗ។ ការធ្វើដូច្នេះនាំឲ្យងាយស្រួលដល់ការរក្សាទុកគ្រប់ពត៌មានទាំងអស់ក្នុងសៀវភៅតែមួយ។
- យកនរណាម្នាក់ទៅជាមួយ ដើម្បីជួយស្តាប់ និងកត់កំណត់ហេតុនានាទុក – និងជួយគាំទ្រលោកអ្នក, បើសិនជាចាំបាច់។
- ស្នើសុំថាតើគេអនុញ្ញាតឲ្យលោកអ្នកអាចថតសម្លេងសន្ទនាទុកបានឬទេ។

ជួនកាល លោកអ្នកអាចនឹងត្រូវការលើកយកការសន្ទនាទៅពិភាក្សាអំពីកង្វល់របស់លោកអ្នកឡើងវិញ។ ខាងក្រោមនេះគឺជារបៀបខ្លះៗក្នុងការធ្វើកិច្ចការនេះ ៖

- សួរសំណួរ។ “តើលោកណែនាំអំពីរឿងអ្វី...”
- និទានប្រាប់អំពីរឿងអ្វីមួយ ដែលកំពុងកើតមានក្នុងជីវិតរបស់កូនលោកអ្នក ដែលលោកអ្នកចង់ពិភាក្សា។ “កាលពីថ្ងៃមួយ នៅក្នុងកិច្ចប្រជុំ IFSP...”
- ផ្លាស់ប្តូរប្រធានបទ។ “ខ្ញុំចង់ជម្រាបប្រាប់លោកនូវរឿងមួយផ្សេងទៀត ដែលនិយាយអំពី...”
- បើវេជ្ជបណ្ឌិតរបស់លោកអ្នកផ្តល់ពត៌មានអ្វីមួយជូនលោកអ្នក ដែលពិបាកយល់, ចូរសួរថាតើលោកអ្នកអាចទូរស័ព្ទទាក់ទៅគាត់ ដើម្បីពិភាក្សាអំពីចម្ងល់នានារបស់លោកអ្នកនៅពេលក្រោយបានឬទេ។
- បើវេជ្ជបណ្ឌិតរបស់លោកអ្នកមិនអាចចូលរួមកិច្ចប្រជុំ IFSP បានទេ, នោះចូរសុំគាត់ឲ្យជួយផ្តល់អនុសាសន៍ និងយោបល់ផ្សេងៗ ឲ្យបានមុនកិច្ចប្រជុំចូលមកដល់។

> *“នេះគឺជាអ្វីដែលខ្ញុំនឹងស្នើសុំ ឬសាកសួរនៅក្នុងកិច្ចប្រជុំ IFSP របស់កូនខ្ញុំ។ តើលោកយល់យ៉ាងណាដែរ?”*

ចូរចែករំលែកគំនិតយោបល់របស់វេជ្ជបណ្ឌិតលោកអ្នកជាមួយក្រុមការងារ IFSP ។

វេជ្ជបណ្ឌិតរបស់លោកអ្នកអាចសម្ព័ន្ធមិត្តរបស់លោកអ្នកក្នុងការជួយលោកអ្នក ដើម្បីស្វែងរកសេវានានា ដែលលោកអ្នកជឿថា កូនរបស់លោកអ្នកត្រូវការ។

- ចូរនិយាយជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នកអំពីអ្វីដែលលោកអ្នកគិតថា លោកអ្នកត្រូវការ។ បើវេជ្ជបណ្ឌិតរបស់លោកអ្នកយល់ព្រម, នោះសូមសុំគាត់ឲ្យសរសេរសំបុត្រមួយច្បាប់ ទៅកាន់ក្រុមការងារ IFSP ដើម្បីពន្យល់ប្រាប់ពួកគេអំពីអនុសាសន៍នានាដែលទទួលបានពីការរួមគំនិតរបស់លោកអ្នក។
- ចូរសួរវេជ្ជបណ្ឌិតរបស់លោកអ្នក ថាតើសមាជិកនៃក្រុមការងារអាចទូរស័ព្ទទៅពិភាក្សាអំពីអនុសាសន៍នានាជាមួយគាត់បានឬទេ។

## ធ្វើបច្ចុប្បន្នភាព

នៅក្នុងអំឡុងពេលជួបពិនិត្យសុខភាពពិសិដកុមារ (Well Child visits) ឬពេលជួបពិនិត្យសុខភាពផ្សេងៗទៀត, ចូរប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នកអំពីការរីកចម្រើន ដែលកូនរបស់លោកអ្នកកំពុងវិវឌ្ឍន៍នៅក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ។ ចូរសួរសំណួរ និងប្រាប់អំពីកង្វល់នានា ដែលលោកអ្នកមាន ពាក់ព័ន្ធសេវាទាំងនេះ។

របៀបល្អនិងទាក់ទាញការចងចាំក្នុងការធ្វើបច្ចុប្បន្នភាពជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នកគឺការផ្ញើជារូបថតរបស់កូនលោកអ្នកម្តងម្កាល ដោយភ្ជាប់នូវកូនសំបុត្រតូចមួយដើម្បីបញ្ជាក់ប្រាប់អំពីការរីកចម្រើនរបស់កូនលោកអ្នក ៖

> *“នេះគឺជាកូនស្រីខ្ញុំ ដែលកំពុងលេងសប្បាយនៅពេលបាយល្ងាច។ នៅក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យ, ខ្ញុំបានរៀនលើកទឹកចិត្តនាងឲ្យរៀនញាំបាយធម្មតាឲ្យបានច្រើន។ នាងមិនក្អួតចង្អោរ និងយំនៅពេលបាយដូចមុនទៀតទេ ហើយខ្ញុំក៏មិនសូវព្រួយបារម្ភអំពីការធំលូតលាស់ចម្រើនវ័យរបស់នាងទៀតដែរ។ កម្មវិធីអន្តរាគមន៍បឋមវ័យពិតជាបានជួយខ្ញុំ ឲ្យមានទំនាក់ទំនងល្អប្រសើរជាងមុនជាមួយកូនស្រីខ្ញុំ និងគ្រួសាររបស់ខ្ញុំ – ពេលទទួលទានបាយលែងចោទជាបញ្ហាទៀតហើយ! ខ្ញុំសូមអរគុណលោកគ្រូពេទ្យ ដែលបានណែនាំខ្ញុំឲ្យទទួលសេវាកម្មនេះ!”*

# ការធ្វើជាអ្នកគាំពារកម្មវិធីអន្តរាគមន៍បឋមវ័យ

តើលោកអ្នកឲ្យតម្លៃសេវាអន្តរាគមន៍បឋមវ័យឬទេ? តើលោកអ្នកចង់ឲ្យកូនរបស់លោកអ្នកត្រូវបានបញ្ជូនលឿនជាងមុនឬទេ? តើលោកអ្នកគិតថា វេជ្ជបណ្ឌិតត្រូវការយល់ដឹងបន្ថែមទៀតអំពីសេវាអន្តរាគមន៍បឋមវ័យឬទេ? តើលោកអ្នកចង់ធ្វើជាអ្នកគាំពារសេវាអន្តរាគមន៍ (Early Intervention Advocate) ឬទេ?

ឪពុកម្តាយគឺតែងតែជាអ្នកគាំពារដ៏មានឥទ្ធិពល។ ដ្បិតលោកអ្នកមានបទពិសោធន៍ផ្ទាល់ខ្លួន ព្រមទាំងរឿងជីវិតពិតៗ ដើម្បីចែករំលែកដល់អ្នកដទៃ – លោកអ្នកអាចធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមាន។

ខាងក្រោមនេះគឺជាវិធនការសាមញ្ញៗ ដែលលោកអ្នកអាចអនុវត្ត ដើម្បីផ្សព្វផ្សាយអំពីសារៈសំខាន់ស្តីអំពីសេវាអន្តរាគមន៍បឋមវ័យ ៖

## ផ្សព្វផ្សាយប្រាប់នរណា...

ចាប់ផ្តើមពីក្រុមមនុស្ស ដែលលោកអ្នកស្គាល់ និងស្និទ្ធស្នាល – ប្រាប់គ្រួសារ និងមិត្តភក្តិរបស់លោកអ្នកឲ្យបានយល់ជ្រាបអំពីសេវាអន្តរាគមន៍បឋមវ័យ និងរបៀបដែលសេវាកម្មនេះបានជួយកូន និងគ្រួសាររបស់លោកអ្នក។

ចែករំលែកសារនេះជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក, ហើយបន្ទាប់មក ស្នើសុំចែករំលែកសាររបស់លោកអ្នកជាមួយបុគ្គលិក និងគូកនរួវវិជ្ជាជីវដទៃទៀតរបស់គាត់។

ចូលរួមជាមួយក្រុមប្រឹក្សាសម្របសម្រួលអន្តរទីភ្នាក់ងារតំបន់ខោនធី (County Interagency Coordinating Council) ប្រចាំមូលដ្ឋានរបស់លោកអ្នក។ លោកអ្នកនឹងបានជួបមនុស្សដទៃៗទៀត ដែលមានមនោសញ្ចេតនាក្នុងការផ្សព្វផ្សាយសេវាអន្តរាគមន៍បឋមវ័យដូចជាលោកអ្នកដែរ។ ចូរស្នើសុំអ្នកសម្របសម្រួលធនធានគ្រួសារ (Family Resources Coordinator, FRC) របស់លោកអ្នកឲ្យបង្ហាញប្រាប់អំពីរបៀបចូលរួមក្នុងក្រុមនេះ។

បើលោកអ្នកពុំមាន FRC ទេ, នោះលោកអ្នកអាចទូរស័ព្ទទាក់ទងទៅលេខ 1-800-322-2588 (នៃបណ្តាញឆ្លើយតបវិបត្តិសុខភាពទាន់ហេតុការណ៍) ហើយសុំនិយាយជាមួយបុគ្គលិក FRC ប្រចាំបំបន់ខោនធីរបស់លោកអ្នក។

បើលោកអ្នកពូកែនិយាយលើវេទការសាធារណ្ណ, នោះលោកអាចចូលរួមក្នុងក្រុមយុទ្ធនាការមាតាបិតា (Parent Panels) ដើម្បីធ្វើយុទ្ធនាការផ្សព្វផ្សាយផ្លូវការ។

## អ្វីដែលត្រូវនិយាយក្នុងយុទ្ធនាការផ្សព្វផ្សាយ...

បណ្តាជនខ្លះចង់ស្តាប់អំពីការបកស្រាយអំពីលទ្ធផលនៃការរកឃើញពីការសិក្សាស្រាវជ្រាវលើសេវាអន្តរាគមន៍បឋមវ័យ។ តែសម្រាប់មនុស្សភាគច្រើន, ការនិទានអំពីរឿងជីវិតជាក់ស្តែងគឺជារឿងសំខាន់ ដែលអាចធ្វើឲ្យគេងាយស្រួលយល់អំពីរបៀប ដែលកម្មវិធីមួយនេះបានធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមានដល់ជីវិតប្រចាំថ្ងៃរបស់ក្មេង និងគ្រួសាររបស់ក្មេង។ រឿងជីវិតជាក់ស្តែងគឺជារឿង ដែលមានឥទ្ធិពលជួយជម្រុញយើង ឲ្យឆ្ពោះទៅធ្វើការផ្លាស់ប្តូរអ្វីមួយ។

តើរឿង ឬឧទាហរណ៍ប្រភេទណា ដែលលោកអ្នកចង់ចែករំលែក ដើម្បីនាំឲ្យមានការប្រែប្រួលដក់ជីវិតក្នុងចំណុចមួយ ឬចំណុចជាច្រើនពីការសិក្សាស្រាវជ្រាវខាងក្រោមនេះ?

## សេវាអន្តរាគមន៍បឋមវ័យជួយគ្រួសាររបស់ក្មេងឲ្យអាចសម្របសម្រួល និងមានដំណើរប្រព្រឹត្តិទៅជាប្រក្រតី។

តើជំនួយដែលកូនរបស់លោកអ្នកកំពុងទទួល ធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមានក្នុងគ្រួសាររបស់លោកអ្នកទេ? តើវាជួយកាត់បន្ថយភាពតានតឹង និងការព្រួយបារម្ភរបស់លោកអ្នកទេ? តើលោកអ្នកបានរៀនអ្វីខ្លះ ដែលនាំឲ្យលោកអ្នកមានអារម្មណ៍ល្អអំពីទំនាក់ទំនងជាមួយកូនរបស់លោកអ្នក?

## សេវាអន្តរាគមន៍បឋមវ័យជួយក្មេង ឲ្យឈានទៅសម្រេចបាននូវអាទិភាពនៃជីវិតរបស់ពួកគេ។

តើលោកអ្នកមានសង្ឃឹមយ៉ាងណាខ្លះសម្រាប់កូនរបស់លោកអ្នក? តើសេវាអន្តរាគមន៍បឋមវ័យបានជួយ ហើយវានឹងបន្តជួយកូនរបស់លោកអ្នករបៀបណា?

## ប្រសិទ្ធភាពខ្ពស់បំផុតនៃកម្មវិធីសេវាអន្តរាគមន៍បឋមវ័យគឺត្រូវចាប់ផ្តើមក្នុងបឋមវ័យ។

តើអ្វីទៅដែលបានធ្វើឲ្យលោកអ្នកចាប់ផ្តើមព្រួយបារម្ភដំបូងបង្អស់អំពីកូនរបស់លោកអ្នក? តើវេជ្ជបណ្ឌិតបានឆ្លើយតបនឹងបញ្ហារបៀបណា ឬតើលោកអ្នកមានបំណងចង់ឲ្យវេជ្ជបណ្ឌិតបានឆ្លើយតបនឹងបញ្ហានេះរបៀបណា? សូមពន្យល់អំពីរបៀបដែល FRC ជួយលោកអ្នក ដើម្បីស្វែងរកសេវា, ធនធាន, ប្រាក់ជំនួយ, និងពត៌មានសំរាប់ការទាក់ទងផ្សេងៗ។

## ប្រសិទ្ធភាពខ្ពស់បំផុតនៃកម្មវិធីសេវាអន្តរាគមន៍បឋមវ័យគឺពាក់ព័ន្ធនឹងមាតាបិតា។

តើលោកអ្នកបានចូលរួមដោយរបៀបណា? តើលោកអ្នកចូលចិត្តអ្វីខ្លះអំពីការចូលរួមនេះ?

ដំណឹងសំខាន់ ៖ កម្មវិធីសេវាអន្តរាគមន៍បឋមវ័យត្រូវបានដាក់ឲ្យបម្រើការជូនបណ្តាក្មេងតូចៗ និងគ្រួសាររបស់ក្មេងទាំងនេះ។ ដូច្នេះ *ចូរស្វែងរកកម្មវិធីនេះភ្លាម ដ្បិតទារកតូចខ្ចីពុំមានពេលរង់ចាំយូរតទៀតទេ។*

---

ដើម្បីស្វែងយល់ពត៌មានពិស្តារបន្ថែម, សូមទាក់ទង ៖


**Early Support for Infants and Toddlers**

Department of Early Learning
PO Box 40970 • Olympia WA 98504-0970
Phone (360) 725-3500 • Fax (360) 413-3482
www.del.wa.gov/esit

**Family to Family Health Information Center - A program of PAVE**
**Family Voices of Washington**
Phone (253) 565-2266 • (800) 572-7368
www.familyvoicesofwashington.com
www.wapave.org



ការរើសអើងត្រូវបានហាមឃាត់ក្នុងគ្រប់កម្មវិធី និងសកម្មភាពទាំងអស់។ គ្មានជនណាម្នាក់គួរត្រូវគេបដិសេធ មិនយល់ព្រមឲ្យទទួលសេវាកម្ម ដោយផ្អែកលើមូលដ្ឋានពូជសាសន៍, ពណ៌សម្បុរ, សាសនា, គោលជំនឿ, សញ្ជាតិដើម, ភេទ, អាយុ, ឬពិការភាពឡើយ។


Washington State Department of
Early Learning

Early Support
for Infants
and Toddlers

PO Box 40970 • Olympia WA 98504-0970
ទូរស័ព្ទ ៖ (360) 725-3500 • ទូរសារ ៖ (360) 413-3482
www.del.wa.gov/esit


DEL 11-008 CA (8/11)